ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**តាមរយៈ៖ -លោកប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**
**-លោកជំទាវឧត្តមសេនីយ៍ឯក ចេង.ប៉ុណ្ណា សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពី ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៩ខែ ឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបថា៖ នៅថ្ងៃព្រហស្បតិ៍ ប្រាំបួនកើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបប្រាំបួន ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ វេលាម៉ោង១៥:៣០នាទីរសៀល អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៩ខែ ឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្ត នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។**

## ក. សមាសភាពចូលរួម

- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ
- ឯកឧត្តម កែន សត្ថា រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង នៃ ខ.ភ.ម និងជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ព្រមទាំង ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន ទីប្រឹក្សា និងក្រុមការងារតំណាង ក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបប្រមាណ ៨៥រូប ស្រី៣០រូប។

## ខ. របៀបវារៈនៃកិច្ចប្រជុំ

១-ពិនិត្យលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៩ខែ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២-ពិភាក្សាលើការវាយតម្លៃចំណាត់ថ្នាក់លេខ៣ របស់សហរដ្ឋអាម៉េរិក លើការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**គ. មតិស្វាគមន៍ និងបើកកិច្ចប្រជុំ**

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានថ្លែងនូវការស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានមកចូលរួមក្នុងកិច្ចប្រជុំនៅពេលនេះ។ ឯកឧត្តមអភិ បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវខ្ពស់ របស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីទាំងអស់នៅក្នុង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់ផងដែរ។

ក្រៅពីប្រជុំត្រួតពិនិត្យរបាយការណ៍រយៈពេល ០៩ខែ របស់ គ.ជ.ប.ជ ឯកឧត្តមអភិ សូមឱ្យអង្គពិធី បន្តយកចិត្តទុកដាក់ និងរួមសហការគ្នាក្នុងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព និងបង្កើនការយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋ និងមន្ត្រីបម្រើការងាររបស់យើង ពិសេសនៅតំបន់ដែលមានភាពងាយរងគ្រោះ។ ឯកឧត្តមអភិ ក៏បានលើកឡើងពីការប្រែប្រួលនៃបទល្មើសមួយចំនួន ជាពិសេស អំពើឆបោកតាមប្រព័ន្ធ បច្ចេកវិទ្យាដែលមានលក្ខណៈជាសកល ហើយប្រទេសនៅតំបន់អាស៊ានមួយចំនួន ត្រូវបានប្រើប្រាស់ក្នុងការទាក់ទាញឱ្យមកបម្រើការងារ តាមរយៈការសន្យាផ្សេងៗ។ ដោយឡែក ចំពោះការធ្វើរបាយការណ៍ សុំពិនិត្យទៅលើរបៀបធ្វើរបាយការណ៍ និងសូចនាករមួយចំនួនពីបណ្តាតួអង្គពាក់ព័ន្ធ ដើម្បីរកវិធីសាស្ត្រកែលម្អឱ្យកាន់តែមានភាពល្អប្រសើរទៅលើរបាយការណ៍។

ជាកិច្ចបន្ទាប់ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានគោរពរាយការណ៍ និងធ្វើបទបង្ហាញដោយសង្ខេប ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៩ខែ ឆ្នាំ២០២៥ ជូន ឯកឧត្តមអភិសន្តិបណ្ឌិត និងអង្គប្រជុំទាំងមូលបានជ្រាប។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយ មានការសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិនានា ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

១-ការបង្ការទប់ស្កាត់៖ បានផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ និងសាធារណជន បានចំនួន ១៤៩.១៩០លើក មានអ្នកចូលរួម ៧.៨៣៣.៧៨៥នាក់ ស្រី ៣.៩០៨.៩៤៧នាក់។

២-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ៖ បានបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប ១៨០ករណី មានការកើនឡើង ២៦% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៤ ក្នុងនោះ ឃាត់ខ្លួនជនសង្ស័យបានចំនួន ២៧៤នាក់(ស្រី ៣៧នាក់ ជនបរទេស ៣៦នាក់ មាន ៤សញ្ជាតិ) និងបានផ្តន្ទាទោសដាក់ពន្ធនាគារ ១០១នាក់ និងសង្គ្រោះជនរងគ្រោះ ចំនួន ៥៨៥នាក់(ស្រី ៣៧២នាក់) អនីតិជន ២១២នាក់ រួមមាន៖ ករណីអំពើជួញដូរមនុស្ស ៧៩ករណី និងអំពើធ្វើអាជីវកម្មផ្លូវភេទ ១០១ករណី។

៣-បានទទួលជនរងគ្រោះទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះទាំងក្នុងប្រទេស និងពីក្រៅប្រទេស សរុបចំនួន ៣២៤នាក់(ស្រី ២២៧នាក់ អនីតិជន ៨១នាក់) និងបានផ្តល់សេវាគាំទ្រ ស្តារនីតិសម្បទា ៣២៤នាក់ ធ្វើសមាហរណកម្មទៅសហគមន៍វិញ ១៨៦នាក់ ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសកំណើតវិញ ២៧នាក់ មាន ៥សញ្ជាតិ បានតាមដានករណីជនរងគ្រោះក្រោយធ្វើសមាហរណកម្ម ២០៩នាក់ និងបិទករណី ៨២នាក់។

៤-បានលើកកម្ពស់សមត្ថភាពតាមរយៈការបណ្តុះបណ្តាល ចំនួន ១៨៨វគ្គ មានអ្នកចូលរួម ៧.១៧៩នាក់ ស្រី ៣.១២២នាក់។

កិច្ចពិភាក្សាបន្ត គឺពិភាក្សាទៅលើការដាក់ចំណាត់ថ្នាក់លេខ ៣ របស់សហរដ្ឋអាម៉េរិក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌៖ សំណូមពរបីចំណុច ១-ប្តូរបែបបទ និងទម្រង់នៃការធ្វើរបាយការណ៍ គឺប្តូរទាំងរបៀបរបប និងលក្ខខណ្ឌបច្ចេកទេស។ ២-រកអ្នកជំនាញមកជួយមើល និងជួយរៀបចំធ្វើរបាយការណ៍ ពិសេស ពាក់ព័ន្ធនឹងការឆបោកតាមប្រព័ន្ធអនឡាញ។ ៣-ពិនិត្យកែសម្រួលក្របខណ្ឌច្បាប់ពាក់ព័ន្ធ ដើម្បីតាមឱ្យទាន់ស្ថានភាពនៃការប្រែប្រួលបទល្មើស។

- ឯកឧត្តម ស៊ា កុសល រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមអង្គពិធីយកចិត្តទុកដាក់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន ដែលជាបញ្ហាសកល និងបានដាក់បញ្ចូលទៅក្នុងការចរចាសន្តិភាពកម្ពុជា-ថៃ។

- ឯកឧត្តម នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរង នៃ ខ.ភ.ម និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សំណូមពរជាវិធានចំនួន៥ចំណុច នៅក្នុងការបង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទ៖ ១-ការគ្រប់គ្រង (ក្រុមគ្រួសារ សាលារៀន និងមន្ត្រីមូលដ្ឋាន)។ ២-ការអប់រំ ពិសេសយុវជន។ ៣-ការអនុវត្តច្បាប់ ពង្រឹងមន្ត្រីអនុវត្តច្បាប់ និងតុលាការ។ ៤-ការបំផុសចលនាបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស គឺការប្រមូលធនធានមនុស្ស ធនធានហិរញ្ញវត្ថុដើម្បីគាំទ្រនគរបាលប៉ុស្តិ៍នៅតាមមូលដ្ឋាន និងមានការលើកទឹកចិត្ត។ ៥-ការផ្សព្វផ្សាយព័ត៌មាន។ ឯកឧត្តម ក៏បានគាំទ្រមតិចូលរួមរបស់ឯកឧត្តម កេង សុម៉ារិទ្ធ ពាក់ព័ន្ធនឹងការជួលអ្នកជំនាញដើម្បីមកជួយរៀបចំរបាយការណ៍ និងការសម្រួលបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន។

## ឃ. មតិបូកសរុប និងអនុសាសន៍ណែនាំ

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** បានឯកភាពចំពោះការលើកឡើងរបស់សមាជិក ក្នុងកិច្ចប្រជុំ និងលើកទឹកចិត្តឱ្យមានការចូលរួមពិភាក្សាបន្តទៀតចំពោះនិយមន័យ Scams Online ឬ Online Scams ឬ Online. ទាក់ទងនឹងសៀវភៅគោល ពាក់ព័ន្ធនឹង Scams Online **ឯកឧត្តមអភិ** បានណែនាំឱ្យក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យលទ្ធភាពដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសាលារដ្ឋ ព្រោះនៅបណ្តាប្រទេសជឿនលឿនដូចជាសិង្ហបុរី បានដាក់បញ្ចូលតាំងពីថ្នាក់មត្តេយ្យសិក្សា។

ដោយឡែកពាក់ព័ន្ធនឹងការងារបង្ការទប់ស្កាត់ **ឯកឧត្តមអភិ** បានមានណែនាំឱ្យ គ.ជ.ប.ជ និងក្រសួងទេសចរណ៍ ត្រូវសហការគ្នាប្រមូលធាតុចូល ដើម្បីបង្កើតវីដេអូផ្សព្វផ្សាយ គឺ វីដេអូដែលធ្វើការផ្សព្វផ្សាយពីការបង្ការទប់ស្កាត់ និងវីដេអូបង្ហាញពីភាពវិជ្ជមានរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គោលបំណងដែលត្រូវបង្កើតវីដេអូនេះឡើង គឺដើម្បីស្តារមុខមាត់កម្ពុជាឡើងវិញ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** បានបញ្ជាក់បន្ថែមថា យើងមិនអាចពឹងលើកម្លាំងនៅថ្នាក់ជាតិទាំងស្រុងបានទេ ដូច្នេះធនធានមនុស្ស នៅមូលដ្ឋានពិតជាមានសារៈសំខាន់ សព្វថ្ងៃមន្ត្រីប៉ុស្តិ៍រដ្ឋបាលមូលដ្ឋានមានចំនួនតិច ដែលត្រូវពង្រឹង និងបំពេញបន្ថែម ហើយជ្រើសរើសមនុស្សដែលរស់នៅទីនោះតែម្តង ដើម្បីជួយសម្រួលការងារនៅមូលដ្ឋានឱ្យបានទាន់ពេលវេលា។ ក្រសួងមហាផ្ទៃ ក៏បានគិតគូរដើម្បីលើកទឹកចិត្ត ដល់មន្ត្រីដែលសកម្មនិងបំពេញការងារបានល្អនៅក្នុងវិស័យ Scams Online និងវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ជាថ្មីម្តងទៀត **ឯកឧត្តមអភិ** បានណែនាំឱ្យ គ.ជ.ប.ជ ត្រូវលើកយក CASEs សំខាន់ៗ ដែលមាននៅក្នុងឆ្នាំ២០២៥ ដំណើរការពី A ដល់ Z ហើយត្រូវផ្សព្វផ្សាយដល់បណ្តាដៃគូពាក់ព័ន្ធឱ្យបានដឹង និងប្រមូលធាតុចូលផ្សេងៗដែលនៅមានភាពខ្វះចន្លោះ ដើម្បីបំពេញបន្ថែមក្នុងការកែសម្រួលរបាយការណ៍។

**ឯកឧត្តមអភិសន្តិបណ្ឌិត** ក៏បានផ្តល់អនុសាសន៍មួយចំនួនដូចជា៖

- ទិន្នន័យដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅកម្ពុជា សុំយកទិន្នន័យពី គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាគោល និងដើម្បីផ្សព្វផ្សាយ។

- សូមពង្រឹងក្រុមការងារ ពិនិត្យលើរចនាសម្ព័ន្ធ ពិសេស ការតម្រង់ទិស របៀបរបបនៃការធ្វើរបាយការណ៍ និងត្រូវកំណត់អត្តសញ្ញាណជនរងគ្រោះ និងជនល្មើស ឱ្យបានច្បាស់លាស់។

- ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើ SCAMING ក្នុងនោះអគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវសម្រួចទៅលើការកំណត់អត្តសញ្ញាណ ជាការជួញដូរ ការស្ម័គ្រចិត្ត ដែលអាចឈានទៅបង្ក្រាបអ្នកពាក់ព័ន្ធទាំងអស់ និងគិតគូពីទំហំទិន្នន័យដែលត្រូវផ្សព្វផ្សាយ។ អគ្គស្នងការ អគ្គស្នងការរង ត្រូវសហការជាមួយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តំណាងក្រុមហ៊ុន META និងក្រុមហ៊ុនតេលេក្រាម ប្រចាំនៅកម្ពុជា ដើម្បីពិនិត្យមាតិកាឆបោកមួយចំនួនដែលបានផ្សព្វផ្សាយ។

- គ.ជ.ប.ជ គិតគូរពេលវេលាសមស្របណាមួយក្នុងការអញ្ជើញអង្គការពាក់ព័ន្ធរបស់សហភាពអឺរ៉ុប UN, LICADO, ADHOC...ដើម្បីផ្តល់ និងផ្លាស់ប្តូរព័ត៌មាន។

- ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ ត្រូវចូលរួមសហការគ្នាអនុវត្តផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញឱ្យមានប្រសិទ្ធភាព។ មានបីដំណាក់កាលនៃការអនុវត្តការទប់ស្កាត់អំពើជួញដូរមនុស្ស និង SCAMS ONLINE ក្នុងនោះដំណាក់កាលទី១ គឺគណៈបញ្ជាការឯកភាពខេត្ត ដំណាក់កាលទី២ គឺក្រុមការងារក្រសួងដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិ ជាមួយក្រុមការងារចំពោះកិច្ច និងដំណាក់កាលទី៣ គឺថ្នាក់ជាតិ ដែលមានសម្តេចបវរធិបតី ជាប្រធាន។

- គួរមានភាពច្នៃប្រឌិត និងការកែលម្អអំពីរបៀបរបប ក្នុងការរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ធ្វើយ៉ាងណា ឱ្យមានភាពទាក់ទាញ។

- តាមបណ្តាក្រសួង ស្ថាប័ន ត្រូវយកចិត្តទុកដាក់ទៅលើការធ្វើរបាយការណ៍ និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ធ្វើការបូកសរុបឱ្យទាន់ពេលវេលា។

ជាទីបញ្ចប់ ឯកឧត្តមអភិសន្តិបណ្ឌិត បានថ្លែងអំណរគុណចំពោះគ្រប់ការចូលរួម និងការលះបង់អស់ពីកម្លាំងកាយចិត្ត បញ្ញា ស្មារតី ធនធានថវិកា ពេលវេលា ប្រកបដោយការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ និងសូមជូនពរប្រទះនូវពុទ្ធពរទាំងបួនប្រការ ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ច។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំបី និងសូន្យនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងភាពស្និទ្ធស្នាល។

អាស្រ័យហេតុនេះ សូមលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាប ជារបាយការណ៍។

ថ្ងៃ.សុ.ក្រ..១០កើត.ខែ.កត្តិក...ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩
រាជធានីភ្នំពេញថ្ងៃទី..៣១... ខែ....១០....ឆ្នាំ២០២៥
អ្នកធ្វើរបាយការណ៍

វរសេនីយ៍ឯក.អ៊ុច ចាន់ឆា

ឯកភាព និងសូមគោរពជូន
លោកជំទាវ អគ្គលេខាធិការ មេត្តាជ្រាបជារបាយការណ៍
ថ្ងៃទី...៣..... ខែ..វិច្ឆិកា... ឆ្នាំ២០២៥
**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

ឧត្តមសេនីយ៍ទោ. ថោង_វុទ្ធី

ឯកភាព និងសូមគោរពជូន
លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាប។
ថ្ងៃទី...៣..... ខែ..វិច្ឆិកា... ឆ្នាំ២០២៥
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ
07/11/25

ជូ_ប៊ុនអេង